# ចង្កើះមួយបាច់ គេកាច់មិនបាក់



## ចង្កើះមួយបាច់ គេកាច់មិនបាក់

សេរីការ : មហាវិថីគ្មានទ្វារ វាបើកច្រកឱ្យអស់ផ្លូវតូចៗចូលបាន

ជាពាក្យស្លោក ដែលខ្មែរយើងតែងតែញជានិច្ច ក្នុងការរស់នៅជាធម្មតា របស់មនុស្សលោកយើង ព្រោះគំនិតដែលមានក្នុងពាក្យស្លោកនេះជា ធាតុធម្មជាតិ ដែលមាននៅក្នុងសង្គមមនុស្សនិមួយៗ។

តាំងតែពីកំណើតដើម របស់មនុស្ស យើងដឹងថា មនុស្សតែងតែឲតម្លៃ ទៅនឹងការរស់រួម បង្កើតជាក្រុម ជាសង្គម ដើម្បីបង្កើតជា កម្លាំងរួម ក្នុងគោលបំណង ការពារសិទ្ធិផ្ទាល របស់ខ្លួន ក្នុងប្រយោជន៍រួម របស់ក្រុម ឬ សង្គមរបស់ខ្លួន។ ដូច្នេះ ប្រយោជន៍បុគ្គលនិមួយៗ ពុំអាចមានកើត នូវការពារបិតថេរបាន បើប្រសិនជា បុគ្គលនោះរស់ឯកោ គ្មានសម្ព្យក្រុម ឬ សង្គមជា ជំរកនោះទេ។

យួនចូលមកនៅក្នុងស្រុកខ្មែរជាពួក ជាក្រុម គេនាំគ្នា បង្កើតសមាគម ដើម្បីការពារសហគមន៍គេ សំរាប់រស់នៅឲមានសុវត្ថិភាព សំរាប់ជនជាតិយួន ចំណែកសហគមន៍ចិន គេមានអុងប៉ាង ជួយមើលការខុសត្រូវ ជួយសំរួលការរស់នៅ ដល់ជនជាតិគេ ដើម្បីឈរឲជាប់មាំក្នុងទឹកដីខ្មែរ សំរាប់អនាគតជនជាតិគេ។ ចិនយួន នៅស្រុកខ្មែរ អ្វីដែលគេធ្វើ គឺគេនាំគ្នា

## ចង្កើះមួយបាច់ គេកាច់មិនបាក់

កសាង មូលដ្ឋានជីវិតសហគមន៍ របស់ពួកគេនៅលើទឹកដីខ្មែរ ដែល គេជ្រើសរើសសំរាប់រស់នៅ។ របងការពារសហគមន៍គេនោះ គឺសាមគ្គីក្នុងគំនិត « ចង្កើះមួយបាច់ គេកាច់មិនបាក់ » នោះឯង ។ ដូច្នេះពាក្យស្លោកខាងលើនេះ ជាឧបាទាន[1] ចិនយួននៅស្រុកខ្មែរ។ ប្រាកដណាស់ថា សហគមន៍ចិនយួន មានការឧបត្ថម្ភ ពីសំណាក់អាជ្ញាធរខ្មែរ ដែលជាអាជ្ញាធរ រស់ក្រោមអំណាចប្រទេសចិន វៀតណាមកុម្មុយនិស្ត តែបើសិនជា ជនជាតិចិនយួនទាំងនោះ គ្មានមារយាទ រស់នៅជា សហគមន៍អនាធិបតេយ្យ គ្មានវិន័យមាំមួនសំរាប់ការរស់នៅ ក៏ពិបាក ប្រទេសចិនយួនជា មាតាប្រទេសគេ និង អាជ្ញាធរខ្មែរជា រណប ជួយ ហើយខ្លាចនោះដែរ។

ជនជាតិ ចិន-យួន នៅស្រុកខ្មែរ គេទុកគ្នាជា ញាតិពន្ធប្រយោជន៍ ហើយគេនាំគ្នា ទុកជនខ្មែរជា ជនបរទេសចំពោះសហគមន៍គេ តែជាពលកម្ម សំរាប់ពាណិជ្ជកម្មគេ គេទុករាជការខ្មែរជា ឈ្នាន់សំរាប់បំរើប្រយោជន៍, ចិនសូកមន្ត្រីឲរស់ជាឈ្នួលបំរើប្រយោជន៍គេ ឯចំណែកមន្ត្រីខ្មែរ សូកយួន ដើម្បីបុណ្យស័ក្តិ និង លុយ សំរាប់រស់ជា ឈ្នួលបំរើប្រយោជន៍ ចិន-យួន។ រួមសេចក្តីមកមន្ត្រីខ្មែរ រស់ក្នុងចំណុះលុយ ចិន-យួន ហើយនៅទីបញ្ចប់ លុយស៊ីពីចិន នាំគ្នាឲទៅយួន, យួន នាំគ្នាយក

---

[1] ឧបាទាន=ន - ការប្រកាន់មាំ,ការប្រតោងចិត្តគំនិត។

## ចង្កឹះមួយបាច់ គេកាច់មិនបាក់

លុយនោះ ទៅចែកចាយជាមួយចិន ហើយនាំគ្នា ធ្វើចៅហ្វាយខ្មែរដងដែល។ លុយដែលរដ្ឋមន្ត្រីខ្មែរ មានពីលក់ជាតិ, យួនហាមមិនឲយកចេញក្រៅប្រទេស ទុកសំរាប់តែចាយធ្វើអ្នកមាន និង អាន់ជ្រី លើក្បាលពលរដ្ឋខ្មែរ។ យួនដឹងទាំងអស់ថាពួករដ្ឋមន្ត្រីខ្មែរ មានលុយដូឡាលាក់ក្នុងផ្ទះ ប៉ុន្មាន, ព្រោះយួនជាអ្នកអនុញ្ញាតពីខាងលើឲអ្នកសូក, សូកពួកពុករលួយ,ដើម្បីឲខ្លាចចិត្តយួនជា ចៅហ្វាយ ខំបំរើយួន ព្រោះយួន ឲទុកលុយក្នុងផ្ទះ សំរាប់ឲតែចាយទិញឡាន ទិញផ្ទះ ធ្វើជាសេដ្ឋី ដើម្បីឲរាស្ត្រខ្មែរស្អប់ខ្ពើម ហើយនាំគ្នាខ្លាចរាស្ត្រខ្លួនឯក នាំគ្នាសុំយួនឲការពារខ្លួន ធ្វើភាគនៃបញ្ជីជាមួយយួន គឺកាត់ទឹកដីខ្មែរទៅឲយួន សំរាប់ធ្វើជា សេដ្ឋី និង ជាមេចោរលួចជាតិ។

របបនយោបាយអាយ៉ងយួននៅភ្នំពេញបច្ចុប្បន្ន ជារបបចោរម័ទ (kleptocratie) គឺជា របបរក់ខាងលួចនិង ពុករលួយ ដោយយកអំណាចរដ្ឋជា មធ្យោបាយ សំរាប់លួចជាតិ និង ប្រជាពលរដ្ឋ, បើនិយាយឲខ្លីគឺ របបចោរប្លន់ជាតិនោះឯង។

របបចោរម័ទនេះ ជាមហាគ្រោះថ្នាក់ដល់ជាតិខ្មែរណាស់ ព្រោះវាយកយួន ដែលជាបរទេស មានមហិច្ឆិតាជានិច្ចលួចទឹកដីខ្មែរ សំរាប់ការពារខ្លួនវា ដូរនឹងទឹកដីខ្មែរ ដែលយួនចង់បាន សំរាប់រស់ ជាចោររក់ខាងលួច។ រាជរដ្ឋាភិបាលខ្មែរបច្ចុប្បន្ន ដឹកនាំដោយ ហ៊ុន សែន ជារាជរដ្ឋាភិបាលចោរម័ទ លួចអ្នកក្រ ដើម្បី បំរើប្រយោជន៍អ្នកមាន ដែលសុទ្ធតែមានកំណើត ជា

## ចង្កឹះមួយបាច់ គេកាច់មិនបាក់

ជនបរទេស ជាពិសេស ចិន-យួន វានាំគ្នាមករស់នៅស្រុកខ្មែរ ដើម្បី បំផ្លាញសម្បត្តិធម្មជាតិ និង ឆ្លៀតប្រើពលកម្មខ្មែរ ដែលមានតម្លៃថោក ដើម្បី ផលិតវត្ថុគ្រប់បែបយ៉ាង សំរាប់យកទៅលក់ឲឈ្មោះថ្លៃក្នុងផ្សារអន្តជាតិតែប៉ុណ្ណោះ។ ពួកឈ្មួញទាំងនោះគ្មានគំនិតណាមួយគិត អំពីអនាគត ដល់ពលករ (ពលការីនី) ខ្មែរនោះឡើយ។ គេគិតតែឆ្លៀត ប្រើកំឡាំងបាយខ្មែរ ដូចឈ្លើងជញ្ជក់ឈាមមនុស្សនោះឯង។

ចុះនៅឯណាទៅគំនិត « ចង្កឹះមួយបាច់ គេកាច់មិនបាក់ » របស់ខ្មែរ?

ក្នុងការនឿយណាយ ចំពោះមុខអយុត្តិធម៌ និង ការឆ្លៀតប្រើកម្លាំងខ្មែរឥតសំចៃ ដែលបានរៀបរាប់ខាងលើនេះ យើងសង្កេតឃើញជនរងគ្រោះខ្មែរយើង មិនសូវមានប្រតិកម្មថ្នាក់ជាតិនោះទ។ កន្លែងណាមានកើតអយុត្តិធម៌ គឺនាំគ្នាតវ៉ាតែកន្លែងដែលមានកើតហេតុនោះតែប៉ុណ្ណោះ ហើយឥតសូវឃើញមានសាមគ្គី ពីសំណាក់ខ្មែរដទៃនោះទេ។ អចលនៈ[2] នេះ ជាទម្លាប់របស់សង្គមខ្មែរ គឺ « អ្នកទទួលហេតុមិនល្អ គឺជាបាបដែលជននោះ ត្រូវសង នូវអំពើដែលខ្លួនបានធ្វើពីជាតិមុន »។ គំនិតនេះ ជាគំនិតអាត្មានិយម ដែលអ្នកដឹកនាំខ្មែរគ្រប់ជំនាន់ គេឆ្លៀតយកមកប្រើ ជាអាវុធសំរាប់បំបែកសាមគ្គីខ្មែរ

[2] អចលនៈ= ភាពមិនកម្រើក។

# ចង្កើះមួយបាច់ គេកាច់មិនបាក់

មិនមែនគំនិត « ចង្កើះមួយបាច់គេកាច់មិនបាក់ » នោះទេ ហើយពឹងតែលើគេតែប៉ុណ្ណោះ ដូចឧទាហរណ៍មានស្រាប់ : ហ៊ុន សែន ប្លន់ដីរាស្ត្រ បែរជាជនរងគ្រោះនាំគ្នាធ្វើ បណ្តឹងលិខិត សូមចោរម៉េទ អោយដីមកខ្លួនវិញ។ សួរថា តើមានចោរណា មួយលួចហើយមកវិញ ?

អ្វីដែលត្រូវធ្វើ គឺត្រូវនាំគ្នាប្តឹង សុំអោយថាចោរ មានសមត្ថកិច្ច ចាប់ចោរ បែរជានាំគ្នា ទៅអង្វរចោរសុំដីមកវិញ។ ឧទាហរ ណ៏ ច្រើនទៀត ដែលយើងមិនលើកមកបង្ហាញ ព្រោះខ្មែរគ្រប់រូប បានតាមដាន ឃើញភាពមិនជម្មតា នៃទង្វើ ដែលអ្នករង គ្រោះកំពុងធ្វើ ហើយមាន អ្នកបញ្ចោរច្រើនណាស់ ដែលតាំង ខ្លួនជាអ្នកជួយរាស្ត្រ មិនគិតនាំគ្នា ពន្យល់ អ្នករងគ្រោះ អោយ តាមផ្លូវត្រូវ និង មានប្រសិទ្ធិភាពផង បែរជានាំគ្នា ធ្វើញណ ផ្ទើ ចំពោះអ្នកបំពានច្បាប់ សុំគោរពច្បាប់ទៅវិញ។ ទង្វើនេះ មិនមានគំនិត « ចង្កើះមួយបាច់ គេកាច់មិនបាក់ » តែផ្ទុយ ទៅវិញ នាំគ្នាបំផ្លាញគំនិតយុត្តិធម៌ពិត ដែលត្រូវធ្វើ។ បើដឹង ថាធ្វើខុសហើយ ហើយនាំគ្នាធ្វើតទៅទៀត អ្នកដែលបាន ចំណេញគឺពិតជាយួននិងក្រុមបក្សពួក ហ៊ុន សែន នោះហើយ។

ឧទាហរណ៏ករណី លោក ម៉ម សូណង់ដូ គឺត្រូវនាំគ្នាឈប់សុំ តុលាការ របស់ហ៊ុនសែនដោះលែងលោក គឺត្រូវនាំគ្នាប្តឹង ហ៊ុន សែន ពីបទរំលោភលើសិទ្ធិសេរីភាពលោកម៉មសូណង់ដូ ដែល ជាអ្នកសារពត៌មាន ទៅតុលាការជាតិក្តី និង តុលាការ

## ចង្កើះមួយបាច់ គេកាច់មិនបាក់

បារាំងក្តី ព្រោះលោក ម៉ម សូណង់ដូ លោកក៏មាន សញ្ជាតិបារាំងដែរ។ បើ ហ៊ុន សែន ប្រើមធ្យោបាយ ដោយយកតុលាការរណបខ្លួន និង យួន ជាអាវុធ ចុះហេតុអ្វីក៏ខ្មែរ អ្នកប្រជាធិបតេយ្យ និង មិត្តបរទេស ជាអ្នកប្រជាធិបតេយ្យ ខ្លាចប្រើសញ្ជាតិបារាំង របស់លោក ម៉ម សូណង់ដូ មកប្រើ ដើម្បី រកយុត្តិធម៌ឲលោក ម៉ម សូណង់ដូ ហើយឈប់សង្ឃឹមលើ សេចក្តីអត់ឱន ហ៊ុន សែន តទៅទៀត ព្រោះច្បាស់ វាគ្មាននោះឡើយ ព្រោះករណីលោក ម៉ម សូណង់ដូ ជារឿងរបស់យួន ដែលជាចៅហ្វាយ ហ៊ុន សែន។

« ចង្កើះមួយបាច់ គេកាច់មិនបាក់ » ជារឿងចិត្តគំនិតខ្មែរ។ ដូច្នេះ លុះត្រាតែខ្មែរយើង ដូរទំលាប់ថា បុណ្យបាប និង យុត្តិធម៌ ជារឿងពីរដាច់គ្នា។ « បុណ្យបាប » ជារឿងសីលធម៌ ចំណែក « យុត្តិធម៌ » ជារឿងច្បាប់, ដូច្នេះបើរដ្ឋអំណាច រំលោភច្បាប់រដ្ឋ គឺមានតែផ្លូវមួយគត់ ជាផ្លូវត្រូវ គឺធ្វើ « សាមគ្គីភាព » ឲក្លាយទៅជា « ចង្កើះមួយបាច់ គេកាច់មិនបាក់ » ដើម្បី ប្រឈមមុខទល់នឹង អំពើអយុត្តិធម៌ គឺនាំគ្នាក្រោកឈររួមប្រឆាំងនឹង រាជរដ្ឋាភិបាលខ្មែរអាយ៉ងយួន ក្នុងសិទ្ធិ និង អំណាចខ្លួន ដែលមានចែង ក្នុងរដ្ឋធម្មនុញ្ញខ្មែរផង ក្នុងច្បាប់អន្តរជាតិផង និង ក្នុងច្បាប់ធម្មជាតិផង។ មានតែសាមគ្គីភាព ក្នុងសកម្មភាពជាសកម្ម គឺធ្វើបាតុកម្មថ្នាក់ជាតិតាមវិធីអហឹង្សាចេញមុខ ទើបអាច រំលំរបបចោរម៉ែទនៅស្រុកខ្មែរ

យើងបាន។ ហើយវាគ្មានច្បាប់ណា ហាមមិនឲប្រជាពលរដ្ឋទាមទារ ឲរាជរដ្ឋាភិបាល អាយ៉ងយួនបច្ចុប្បន្ន លាលែងពីតំណែងនោះទេ។ បើបក្សសមរង្ស៊ី និង សិទ្ធិមនុស្ស នៅតែមានសង្ឃឹម លើករុណា ហ៊ុន សែន, នោះជាភាព រវើរវាយ របស់ពួកគាត់តែប៉ុណ្ណោះ ហើយពួកគាត់ ជាអ្នកទទួលខុសត្រូវ ចំពោះមុខប្រវត្តិសាស្ត្រខ្មែរ ថាតើ ហ៊ុន សែន ជាជនក្បត់ជាតិ ឬ ពួកគាត់ជាជនក្បត់ជាតិ ក្នុងការធ្វើសហការណ៏ ជាមួយរបបចោរម័ទ ដែលមាន ហ៊ុន សែន ជាប្រមុខ។ ហ៊ុន សែន ប្លន់ជាតិត្រង់ៗ។ ទង្វើនេះ ក្នុងច្បាប់គេទុកជា ចោរប្លន់, ចំណែងអស់លោកតាំងខ្លួន ជាអ្នកប្រឆាំង តែនៅតែធ្វើសហការណ៏ជាមួយចោរប្លន់ ទង្វើនេះ ក្នុងច្បាប់គេទុកលោក ជាចោរប្លន់ដូចគ្នា។ បើអស់លោកចោទ ហ៊ុន សែន ជាជនក្បត់ជាតិ, អស់លោក ក៏ជា ជនក្បត់ជាតិដូច ហ៊ុន សែនដែរ៕